# គោលការណ៍គ្រប់គ្រងអាកប្បកិរិយាបឋមវ័យ

នៅសាលារៀនដើមឈើសិក្សាយើងខ្ញុំមានគោលបំណងផ្តល់ជូនបរិស្ថានសិក្សាមួយប្រកបដោយវិជ្ជមាននិងមានភាពស្ថិតស្ថេរដែលសិស្សអាចលេង និង សិក្សាបាន។ យើងខ្ញុំក៏ធ្វើការក្នុងភាពជាដៃគូជាមួយមាតាបិតាកុមារ ដោយទំនាក់ទំនង ផ្តល់នូវដំបូន្មាន និងការគាំទ្រ ជាពិសេសនៅពេលដោះស្រាយបញ្ហាផ្សេងៗទាក់ទងនឹងអាកប្បកិរិយា។

## ការបង្កើតបរិស្ថានសិក្សាប្រកបដោយការថែទាំ

ដើមឈើសិក្សាជឿជាក់ថាដើម្បីឱ្យបរិស្ថានសិក្សាមានប្រសិទ្ធភាពដែលកុមារអាចអភិវឌ្ឍអាកប្បកិរិយាសមរម្យក្នុងសង្គម និងការសិក្សាគ្រប់ទិដ្ឋភាពនៃជីវិតមត្តេយ្យសិក្សាគឺជារឿងចំបាច់បំផុត។ យើងខ្ញុំខិតខំបង្កើតនូវបរិស្ថានសិក្សាប្រកបដោយការថែទាំដល់កុមារទាំងអស់ដោយៈ

- លើកទឹកចិត្ត និងទទួលស្គាល់នូវអាកប្បកិរិយាល្អៗព្រមទាំងមានវិធីសាស្ត្រដែលមានបិតបេរឆ្លើយតបចំពោះអាកប្បកិរិយាមិនសមរម្យ។
- លើកកម្ពស់ការវាយតម្លៃផ្ទាល់ខ្លួនដោយជំរុញឱ្យកុមារវាយតម្លៃ និងគោរពខ្លួនឯង និងគោរពអ្នកដទៃ។
- ផ្តល់ជូននូវបរិស្ថានប្រកបដោយសុវត្ថិភាព។
- លើកកម្ពស់ដល់ការធ្វើអន្តរាគមន៍បឋមវ័យ។
- ជំរុញឱ្យកុមារមានទំនាក់ទំនងវិជ្ជមានជាមួយមាតាបិតានិងអ្នកថែទាំដើម្បីអភិវឌ្ឍនូវវិធីសាស្ត្រចែករំលែកដើម្បីឱ្យពួកគេចូលរួមក្នុងការអនុវត្តគោលនយោបាយមត្តេយ្យសិក្សា និងនីតិវិធីដែលជាប់ទាក់ទង។
- លើកទឹកចិត្តឱ្យកុមារមានទំនួលខុសត្រូវចំពោះអាកប្បកិរិយារបស់ខ្លួន។
- ពន្យល់ណែនាំពីអាកប្បកិរិយាដែលមិនអាចទទួលយកបាន។
- ធ្វើជាគំរូដ៏ល្អដល់អ្នកដទៃ។

កុមារចាំបាច់ត្រូវរៀនពិចារណាទៅលើទស្សនៈ និងអារម្មណ៍ តម្រូវការចាំបាច់ និងសិទ្ធិរបស់អ្នកដទៃព្រមទាំងផលជះដែលអាកប្បកិរិយារបស់ពួកគេធ្វើទៅលើអ្នកដទៃ ទីកន្លែង និងវត្ថុផ្សេងៗ។ នេះជាកិច្ចការដែលមានលក្ខណៈអភិវឌ្ឍដែលតម្រូវឱ្យមានការគាំទ្រ លើកទឹកចិត្ត ការបង្រៀន និង ការរៀបចំជាគំរូឱ្យបានត្រឹមត្រូវ។ គោលការណ៍ដែលបង្កើតជាមូលដ្ឋានស្តីពីវិធីដែលយើងសម្រេចបានជោគជ័យនូវអាកប្បកិរិយាវិជ្ជមាននិងប្រកបដោយការពិចារណាដែលមានក្នុងកម្មវិធីដើម្បីលើកកម្ពស់ដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈ សង្គម និងអារម្មណ៍ពួកគេ។

## ការជំរុញឱ្យមានអាកប្បកិរិយាវិជ្ជមាន

អាកប្បកិរិយាប្រកបដោយវិជ្ជមានត្រូវបានលើកកម្ពស់តាមរយៈ៖

- ការសរសើរ ការផ្តល់រង្វាន់ និងការលើកទឹកចិត្ត ឧ. លើកមេដៃឡើង ការគោះខ្នងកុមារថើរៗ ញញឹម និង ការប្រើប្រាស់ភាសាវិជ្ជមានជាមួយកុមារ។

- ការប្រើប្រាស់ការសរសើរ ការផ្តល់រង្វាន់ និងការលើកចិត្តនេះជាឧទាហរណ៍ដល់កុមារដទៃដើម្បីលើកកម្ពស់អាកប្បកិរិយាដែលចង់បាន។
- ធ្វើជាគំរូ និងការអភិវឌ្ឍជំនាញសង្គមដូចជាៈ ការចែករំលែក ឥរិយាបទ អនាម័យ និងការបែងចែកការទទួលខុសត្រូវម្តងម្នាក់។
- លើកទឹកចិត្តកុមារឱ្យមានទំនួលខុសត្រូវចំពោះអាកប្បកិរិយាផ្ទាល់ខ្លួន និងទទួលខុសត្រូវចំពោះអ្នកដទៃ ឧ. ការគាំទ្រកុមារម្នាក់ឱ្យប្រាប់ទៅកុមារដទៃ "សូមកុំធ្វើអ៊ីចឹង ខ្ញុំមិនចូលចិត្តវាទេ"។
- រៀងរាល់សប្តាហ៍យើងជ្រើសរើសកុមារ៣នាក់ដែលបានបង្ហាញការវិវត្តន៍ដ៏អស្ចារ្យមិនថាទាក់ទងទៅនឹងការចែករំលែកជំនាញផ្សេងៗ ការអនុវត្តការសរសេរដោយដៃ ។ល។ កុមារទាំងនោះទទួលបានរង្វាន់ជាវិញ្ញាបនបត្រតារាប្រចាំសប្តាហ៍។

**ការគ្រប់គ្រងអាកប្បកិរិយាមិនសមរម្យ**

ចំណុចចាប់ផ្តើមរបស់យើងខ្ញុំគឺគិតទៅលើអាយុ និងដំណាក់កាលអភិវឌ្ឍរបស់កុមារ។
អាកប្បកិរិយាដែលមិនអាចទទួលយកបានរួមមានៈ

- ភាសាមិនសមរម្យ និងពាក្យសំដីប្រមាថមាក់ងាយ។
- មិនគោរពតាមការចែករំលែកទៅតាមវេន និងជំនាញសង្គមផ្សេងៗ។
- បង្កឱ្យមានគ្រោះថ្នាក់ដល់រូបរាងកាយកុមារដទៃ/ខ្លួនឯង ឬបុគ្គលិក
- ការធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់សាលាមត្តេយ្យដដែលច្រើនលើកច្រើនសារ ឬ ធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់កុមារផ្សេងទៀត។
- តែងតែសម្លុតគម្រាមកំហែងអ្នកដទៃ

បុគ្គលិកសាលានឹងព្យាយាមទប់ស្កាត់ស្ថានភាពដែលមិនល្អដែលកើតឡើងដោយធ្វើអន្តរាគមន៍មុនពេលពួកគេវាកើតមាន។ យើងខ្ញុំមានយុទ្ធសាស្ត្រផ្សេងៗដែលយើងខ្ញុំប្រើប្រាស់ដើម្បីដោះស្រាយចំពោះអាកប្បកិរិយាដែលមិនសមរម្យទាំងនោះ។ វិធីសាស្ត្រទាំងនេះមានលក្ខណៈផ្សេងៗគ្នាអាស្រ័យលើអាយុ និងដំណាក់កាលអភិវឌ្ឍរបស់កុមារ ស្ថានភាព និងកត្តាផ្សេងៗដូចជាភាពនឿយណាយ។

**កត្តាទាំងអស់នេះមានដូចជាៈ**

- ការព្រមានដោយប្រើពាក្យសំដីពន្យល់ដល់កុមារ
- ដកយកសម្ភារបរិក្ខារចេញ
- ការបង្វែរស្ថានភាព
- ការយកកុមារចេញពីស្ថានភាព
- ការរំឭក
- និងការប្រាប់កុមារឱ្យឈប់ធ្វើនូវអ្វីដែលគេកំពុងធ្វើ

តែទោះបីជាយ៉ាងណាក៏ដោយ ការផ្តោតការយកចិត្តទុកដាក់របស់យើងខ្ញុំគឺតែទៅលើការលើកកម្ពស់ឱ្យកុមារមានអាកប្បកិរិយាវិជ្ជមាន និងទប់ស្កាត់នូវអាកប្បកិរិយាដែលមិនសមរម្យ។